*[សូមផ្ទៀងផ្ទាត់ តាមការអាន]*

# សុន្ទរកថា

## អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន
## ឧបនាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
## និង ជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម
## តំណាង សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
## នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
## ថ្លែងក្នុង
## ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវ
## អគារស្នាក់ការកណ្តាលរបស់បេឡាជាតិសន្តិសុខសង្គម

ថ្ងៃព្រហស្បតិ៍ ៤ រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី ៦ ខែ កក្កដា គ.ស. ២០២៣

- ឯកឧត្តមបណ្ឌិត **អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ;
- ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, ឧកញ៉ា, លោក, លោកស្រី!

ថ្ងៃនេះ, ខ្ញុំមានកិត្តិយសដ៏ខ្ពង់ខ្ពស់ និង សេចក្តីសោមនស្សយ៉ាងក្រៃលែង ដោយបានទទួលការចាត់តាំងដ៏ខ្ពង់ខ្ពស់ ពីសំណាក់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ធ្វើជាអធិបតី ក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ នូវ **អគារស្នាក់ការកណ្តាលថ្មីរបស់បេឡាជាតិសន្តិសុខសង្គម (ប.ស.ស.)** ។ ក្នុងនាម **សម្តេចតេជោ នាយករដ្ឋមន្ត្រី**, ខ្ញុំសូមសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅ ចំពោះវត្តមានរបស់ឯកឧត្តម, លោកជំទាវ, អ្នកឧញ៉ា, ឧកញ៉ា, លោក, លោកស្រី ដែលបានឆ្លៀតពេលដ៏មានតម្លៃ អញ្ជើញចូលរួមក្នុងពិធី នាព្រឹកនេះ ។

ក្នុងឱកាសដ៏មហោឡារិកនេះ, ខ្ញុំសូមសម្តែងនូវសេចក្តីសាទរ ចំពោះថ្នាក់ដឹកនាំ, មន្ត្រី និង បុគ្គលិក របស់ **ប.ស.ស.** ព្រមទាំងក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ចំពោះការទទួលបាននូវអគារការិយាល័យថ្មីដ៏ធំស្កឹមស្កៃ ដែលមានកម្ពស់រហូតដល់ ២១ ជាន់ និងបំពាក់ដោយប្រព័ន្ធគ្រប់គ្រងទំនើប ដើម្បីលើកកម្ពស់គុណភាព និង ប្រសិទ្ធភាពនៃការផ្តល់សេវាជូនសមាជិក **ប.ស.ស.** ឱ្យកាន់តែប្រសើរ ប្រកបដោយប្រសិទ្ធភាពខ្ពស់ ។ ឆ្លៀតក្នុងឱកាសនេះ, ខ្ញុំសូមកោតសរសើរ និង វាយតម្លៃខ្ពស់ ចំពោះកិច្ចខិតខំរបស់ថ្នាក់ដឹកនាំ, មន្ត្រី និង បុគ្គលិកគ្រប់លំដាប់ថ្នាក់នៃ **ប.ស.ស.** ដែលបានបំពេញការងារ នាពេលកន្លងមក ប្រកបដោយស្មារតីទទួលខុសត្រូវ និង ទទួលបានលទ្ធផលជាផ្លែផ្កាជាច្រើន គួរជាទីមោទនៈ ចាប់តាំងពីស្ថាប័ននេះត្រូវបានបង្កើត រហូតមកដល់បច្ចុប្បន្ន ។

## ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, ឧកញ៉ា, លោក, លោកស្រី!

បន្ទាប់ពីអាចគ្រប់គ្រងបានយ៉ាងល្អ នូវស្ថានភាពនៃជំងឺកូវីដ-១៩, ថ្មីៗនេះ, កម្ពុជាក៏ទទួលបាននូវកិត្តិយសល្បីរន្ទឺ តាមរយៈជោគជ័យដ៏ត្រចះត្រចង់ជាប្រវត្តិសាស្ត្រ គួរជាទី-មោទនៈបំផុត ក្នុងការបំពេញតួនាទីជាប្រធានប្តូរវេន និង ជាម្ចាស់ផ្ទះ នៃកិច្ចប្រជុំកំពូលអាស៊ាន លើកទី ៤០ និង ៤១ និង កិច្ចប្រជុំពាក់ព័ន្ធ នៅឆ្នាំ ២០២២ ព្រមទាំងការទទួលធ្វើជាម្ចាស់ផ្ទះរៀបចំព្រឹត្តិការណ៍កីឡាស៊ីហ្គេមលើកទី ៣២ និង អាស៊ានប៉ារ៉ាហ្គេម លើកទី ១២, ឆ្នាំ ២០២៣, ដែលទើបត្រូវបានបិទបញ្ចប់ បន្ទាប់ពីយើងបានរង់ចាំអស់រយៈពេល ៦៤ ឆ្នាំ ។ សមិទ្ធផលទាំងនេះ បានបង្ហាញឱ្យឃើញថា ព្រះរាជណាចក្រកម្ពុជា មានសមត្ថ-ភាពគ្រប់គ្រាន់ ក្នុងការឆ្លើយតបទៅនឹងបញ្ហាប្រឈមនានា និង អាចចូលរួមក្នុងកិច្ចការតំបន់ និង សកល ប្រកបដោយប្រសិទ្ធភាព, ស្មើសិទ្ធិ និង ស្មើភាព, ក្រោមមគ្គុទេសក៍ដឹកនាំដ៏ភ្លឺស្វាង និង វៃឆ្លាត ប្រកបដោយចក្ខុវិស័យវែងឆ្ងាយ និង ភាពប្រាកដនិយម របស់ **សម្តេច-អគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ។

សមិទ្ធផលដែលកើតចេញពីការខិតខំទាំងនេះ បង្កើតបានជាមូលដ្ឋានគ្រឹះដ៏រឹងមាំ សម្រាប់ការស្តារ និង ជំរុញសកម្មភាពសេដ្ឋកិច្ច ឱ្យវិលត្រលប់ទៅរកប្រក្រតីភាពឡើងវិញ បានយ៉ាងរហ័ស ។ ជាក់ស្តែង, ទោះបីជាត្រូវបានរងផលប៉ះពាល់យ៉ាងខ្លាំង ពីវិបត្តិនៃជំងឺកូវីដ-១៩, សេដ្ឋកិច្ចកម្ពុជា, បន្ទាប់ពីបានធ្លាក់ចុះ ក្នុងអត្រា -៣,១% នៅឆ្នាំ ២០២០, បានស្ទុះងើបឡើងវិញ ក្នុងអត្រា ៣% នៅឆ្នាំ ២០២១, ហើយ ក្នុងឆ្នាំ ២០២២ សម្រេចបានកំណើន ក្នុងរង្វង់

៥,២%, ខណៈដែលឆ្នាំ ២០២៣ កំណើនអាចនឹងមាន ក្នុងរង្វង់ ៥,៦% ដែលនឹងធ្វើឱ្យ **ផសស** សម្រាប់មនុស្សម្នាក់ កើនដល់ ១ ៩៣២ ដុល្លារអាម៉េរិក ធៀបនឹង ១ ៧៨៤ ដុល្លារអាម៉េរិក ក្នុងឆ្នាំ ២០២២ ។ កំណើនសេដ្ឋកិច្ចដ៏ប្រសើរនេះ, មួយផ្នែកធំ, ត្រូវបានគាំទ្រដោយ ៖ **ទី១.**ការបង្កើតបាននូវភាពស៊ាំសហគមន៍ពេញលេញ និង រឹងមាំ ប្រឆាំងនឹងជំងឺឆ្លងដ៏សាហាវ ដោយសារប្រជាពលរដ្ឋកម្ពុជា ជាង ៩០% បានទទួលនូវការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដោយឥតគិតថ្លៃ; និង **ទី២.**ការដាក់ចេញនូវវិធានការអន្តរាគមន៍ផ្នែកសង្គម-សេដ្ឋកិច្ច បានរហ័ស និង ចំទិសដៅ ប្រកបដោយប្រសិទ្ធភាពខ្ពស់ ដើម្បីរក្សាលំនឹងជីវភាពប្រជាជន និង ធានាស្ថិរភាពអាជីវកម្ម, ស្របពេលដែលស្ថានភាពអតិផរណា បន្តស្ថិតក្នុងកម្រិតអាចគ្រប់គ្រងបាន ។

យ៉ាងណាមិញ, រាជរដ្ឋាភិបាលយល់ច្បាស់ថា ដំណើរឆ្ពោះទៅមុខរបស់យើង ពិតជាមិនងាយស្រួលនោះទេ ។ ជាក់ស្តែង, ស្លាកស្នាមនៃជំងឺកូវីដ-១៩ មិនទាន់ផុតរលត់ទាំងស្រុងនៅឡើយ ស្របពេលដែលបញ្ហាប្រឈមជាសកលផ្សេងទៀត, រួមមាន សម្ពាធអតិផរណាជាសកល និង វិបត្តិនៃសង្គ្រាមនៅអ៊ុយក្រែន, បន្តកើតមាន ក្នុងបរិការណ៍បច្ចុប្បន្ន និង អនាគត ដែលពោរពេញដោយភាពមិនប្រាកដប្រជា ។ ក្នុងន័យនេះ, កម្ពុជាពិតជាមានភាព-ចាំបាច់ ក្នុងការពង្រឹង និង អភិវឌ្ឍភាពធន់នៃប្រព័ន្ធគាំពារសង្គម ដើម្បីត្រៀមខ្លួនឆ្លើយតបទៅនឹងវិបត្តិណាមួយដែលអាចកើតមានជាយថាហេតុ ។

**ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, ឧកញ៉ា, លោក, លោកស្រី!**

ទន្ទឹមនឹងការងើបឡើងវិញនៃស្ថានភាពសេដ្ឋកិច្ចជាទូទៅ, ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមកម្ពុជា ក៏បន្តបោះជំហានទៅមុខប្រកបដោយមោទនភាព ផងដែរ ដូចឯកឧត្តមបណ្ឌិត **អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ទើបបានគូសរំលេច នៅក្នុងរបាយការណ៍អម្បាញ់មិញ អំពីវឌ្ឍនភាពនៃប្រព័ន្ធសន្តិសុខសង្គម ដែលជាសសរស្តម្ភគោល ១ ក្នុងចំណោមសសរស្តម្ភទាំង ២ នៃប្រព័ន្ធគាំពារសង្គមកម្ពុជា ។ ទន្ទឹមនេះ, រាជរដ្ឋា-ភិបាលក៏បានផ្តោតការយកចិត្តទុកដាក់ លើការជំរុញការអភិវឌ្ឍប្រព័ន្ធជំនួយសង្គមផងដែរ ដែលជាសសរស្តម្ភគោល ១ ទៀត សំដៅជួយគាំទ្រសុខុមាលភាពរបស់ពលរដ្ឋក្រីក្រ និង ងាយរងគ្រោះ ដែលជាទូទៅ ពុំស្ថិតក្នុងរបបសន្តិសុខសង្គម ។

គិតត្រឹមបច្ចុប្បន្ន, រាជរដ្ឋាភិបាលបានដាក់ចេញ នូវកម្មវិធីជាតិជំនួយសង្គមសំខាន់ៗ មួយចំនួន រួមមាន ៖ កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និង កុមារអាយុក្រោម ២ ឆ្នាំ, កម្មវិធីផ្តល់អាហារតាមសាលារៀន ដោយប្រើប្រាស់កសិផលក្នុងសហគមន៍, កម្មវិធីអាហារូបករណ៍ថ្នាក់បឋមសិក្សា និង មធ្យមសិក្សា សម្រាប់កុមារមកពីគ្រួសារក្រីក្រ, កម្មវិធីរបបគោលនយោបាយ សម្រាប់ជនពិការក្នុងសហគមន៍, និង កម្មវិធីសាច់ប្រាក់ពលកម្ម ។

ជាមួយគ្នានេះ, រាជរដ្ឋាភិបាលកំពុងតែបន្តអនុវត្តនៅឡើយ នូវ **កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និង ងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩** ដើម្បីជួយគាំទ្រជីវភាពគ្រួសារក្រីក្រ និង ងាយរងគ្រោះ ក្នុងដំណាក់កាលស្តារសេដ្ឋកិច្ចឡើងវិញ ។ ចាប់តាំងពីត្រូវបានដាក់ឱ្យអនុវត្ត នៅថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០២០, កម្មវិធីឧបត្ថម្ភសាច់ប្រាក់ពិសេសនេះ បានដំណើរការអស់រយៈពេល **៣៦ ខែ** មកហើយ និង បានផ្តល់ប្រាក់ឧបត្ថម្ភប្រចាំខែ ជូនគ្រួសារក្រីក្រ និង ងាយរងគ្រោះ ចំនួនប្រមាណ **៧០ ម៉ឺនគ្រួសារ**, គ្របសមាជិកប្រមាណ **២,៨ លាននាក់** នៅទូទាំងប្រទេស, ដោយបានប្រើប្រាស់ថវិកាជាតិសុទ្ធសាធ ចំនួនប្រមាណ **១ ១០០ លានដុល្លារអាម៉េរិក** ។ លើសពីនេះ, គ្រួសារងាយរងហានិភ័យ ដែលមានជីវភាពក្បែរបន្ទាត់នៃភាពក្រីក្រ ក៏ត្រូវបានគិតគូរផងដែរ តាមរយៈការដាក់ឱ្យអនុវត្តនូវកម្មវិធីជំនួយសង្គមជាសាច់ប្រាក់ ជូនគ្រួសារងាយរងហានិភ័យ ក្នុងអំឡុងពេលមានសម្ពាធអតិផរណា និង រងផលប៉ះពាល់ធ្ងន់ធ្ងរពីគ្រោះទឹកជំនន់ ។

ប្រព័ន្ធគាំពារសង្គម គឺជាសសរស្តម្ភដែលរួមចំណែកយ៉ាងសំខាន់ ដល់ការកសាងសង្គមមួយ ប្រកបដោយភាពសុខដុម និង ជាមូលដ្ឋានគ្រឹះសម្រាប់ទ្រទ្រង់ និង អភិវឌ្ឍន៍ប្រទេស ឱ្យមានភាពធន់, រឹងមាំ, និរន្តរភាព, សមធម៌ និង បរិយាប័ន្ន ព្រមទាំងជួយឱ្យសង្គមជាតិ អាចសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សំខាន់ៗ ស្របតាមរបៀបវារៈគោលនយោបាយរបស់រាជរដ្ឋាភិបាល ។ ក្នុងន័យនេះ, ការជំរុញការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម មិនត្រឹមតែត្រូវការជាចាំបាច់ នូវកិច្ចសហការរវាងក្រសួង-ស្ថាប័នពាក់ព័ន្ធប៉ុណ្ណោះទេ, ប៉ុន្តែ ថែមទាំងត្រូវការផងដែរ នូវការកសាងយន្តការអភិបាលកិច្ចមួយ ដែលមានភាពរឹងមាំ ដោយប្រកាន់ខ្ជាប់នូវគោលការណ៍តម្លាភាព និង គណនេយ្យភាព ដើម្បីធានាឱ្យបាននូវប្រសិទ្ធភាព និង និរន្តរភាព ។

ជាក់ស្តែង, **ដើម្បីធានាឱ្យមានប្រតិតុល្យការសម្រាប់ប្រព័ន្ធទាំងមូល, ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥** បានកំណត់យកគោលការណ៍អភិបាលកិច្ច

ល្អ ជាមូលដ្ឋានគ្រឹះសម្រាប់ការគ្រប់គ្រងប្រព័ន្ធគាំពារសង្គម ព្រមទាំងបានកំណត់ឱ្យមានការបែងចែកមុខងាររបស់ស្ថាប័នពាក់ព័ន្ធជា ៣ កម្រិត រួមមាន ៖ **កម្រិតគោលនយោបាយ**, **កម្រិតនិយ័តករ** និង **កម្រិតប្រតិបត្តិករ** ។

បន្ទាប់ពីត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០១៧, **ក្រុមប្រឹក្សាជាតិគាំពារសង្គម** បានបំពេញតួនាទីជាសេនាធិការតែមួយរបស់រាជរដ្ឋាភិបាល ក្នុងការពិនិត្យ និង សម្របសម្រួលលើការរៀបចំគោលនយោបាយ ខណៈដែលការកែទម្រង់ស្ថាប័នពាក់ព័ន្ធ ក៏ត្រូវបានធ្វើជាបន្តបន្ទាប់ រួមមាន ៖ ១).ការរៀបចំរចនាសម្ព័ន្ធថ្មីរបស់បេឡាជាតិសន្តិសុខសង្គម (**ប.ស.ស.**) ក្នុងឆ្នាំ ២០២០; ២).ការបង្កើត និង ដាក់ឱ្យដំណើរការ នូវមូលនិធិជាតិជំនួយសង្គម (**ម.ជ.ជ.**) ក្នុងឆ្នាំ ២០២២; និង ៣).ការកែទម្រង់ទីភ្នាក់ងារបញ្ជាក់ចំណាយសេវាមូលដ្ឋានសុខាភិបាល ឱ្យក្លាយជាស្ថាប័នបញ្ជាក់ចំណាយ សម្រាប់ប្រព័ន្ធថែទាំសុខភាពសង្គមទាំងមូល ។

មិនតែប៉ុណ្ណោះ, រាជរដ្ឋាភិបាលក៏បានបង្កើត និង ដាក់ឱ្យដំណើរការ នូវ **និយ័តករសន្តិសុខសង្គម** នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដើម្បីធ្វើនិយ័តកម្ម និង ត្រួតពិនិត្យលើប្រតិបត្តិការ ក្នុងប្រព័ន្ធសន្តិសុខសង្គម ផងដែរ ។ វត្តមានរបស់និយ័តករសន្តិសុខសង្គមមានសារៈសំខាន់ណាស់ ក្នុងការធានាថា កិច្ចដំណើរការគ្រប់គ្រង និង ការចាត់ចែងរបបសន្តិសុខសង្គមនានា ត្រូវបានអនុវត្តប្រកបដោយភាពត្រឹមត្រូវ, តម្លាភាព និង គណនេយ្យភាព ចំពោះសាធារណជន, ជាពិសេស ចំពោះនិយោជក និង កម្មករ-និយោជិត ដែលមានកាតព្វកិច្ចបង់ភាគទានចូលក្នុងមូលនិធិរួមគ្នា ។

### ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, ឧកញ៉ា, លោក, លោកស្រី!

ស្របពេលដែលយើងសម្រេចបាននូវវឌ្ឍនភាពគួរជាទីមោទនៈ ដូចខ្ញុំបានគូសបញ្ជាក់ខាងលើ, យើងក៏មិនគួរមើលរំលងនោះឡើយ នូវបញ្ហាប្រឈម និង ភាពខ្វះចន្លោះមួយចំនួនដែលនៅសេសសល់ ។ ក្នុងនោះ, វិសាលភាពគ្របដណ្តប់នៃប្រព័ន្ធសន្តិសុខសង្គមនៅតែជាបញ្ហាចម្បង ដែលរាជរដ្ឋាភិបាលនឹងត្រូវបន្តការយកចិត្តទុកដាក់ ។ ជាទិសដៅចំពោះមុខ, រាជរដ្ឋាភិបាលនឹងដាក់ចេញ នូវអន្តរាគមន៍មួយចំនួន ដូចខាងក្រោម៖

១. កែសម្រួលកម្មវិធីឧបត្ថម្ភពេលសម្រាលកូន ជូនកម្មករ-និយោជិតជាស្ត្រី និង មន្ត្រីសាធារណៈជាស្ត្រី ទៅជាកម្មវិធីឧបត្ថម្ភសាច់ប្រាក់ ក្នុងអំឡុងពេលមានផ្ទៃពោះ, ពេលសម្រាល និង ក្រោយសម្រាល រហូតដល់កូនមានអាយុ ២ ឆ្នាំ ដូចការអនុវត្ត

សម្រាប់ស្ត្រីមកពីគ្រួសារក្រីក្រមានបណ្ណសមធម៌ ផងដែរ;

២. ដាក់ឱ្យអនុវត្តនូវរបបថែទាំសុខភាព តាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល សម្រាប់បុគ្គលបម្រើការក្នុងសេវាកម្សាន្តទេសចរណ៍ នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ; និង

៣. ដាក់ឱ្យដំណើរការនូវកម្មវិធីជំនួយសង្គមផ្នែកបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រាប់យុវជនមកពីគ្រួសារក្រីក្រ ។

បន្ថែមលើនេះ, ដើម្បីបន្តអភិវឌ្ឍន៍ប្រព័ន្ធគាំពារសង្គមឱ្យកាន់តែរឹងមាំ, រាជរដ្ឋាភិបាលបាន និង កំពុងគិតគូរអំពីគោលដៅរយៈពេលវែង សម្រាប់បន្តអភិវឌ្ឍន៍ប្រព័ន្ធគាំពារសង្គម ឱ្យមានលក្ខណៈកាន់តែគ្រប់ជ្រុងជ្រោយ, មានភាពធន់, ស្វ័យប្រវត្តិ និង សមាហរណ, និង ជាប្រព័ន្ធដែលទ្រទ្រង់សុខុមាលភាពប្រជាពលរដ្ឋពេញមួយវដ្តជីវិត, ជាពិសេស ក្នុងអំឡុងពេលមានវិបត្តិ ឬ គ្រោះអាសន្នណាមួយ ។ ហេតុនេះ, ក្រុមប្រឹក្សាជាតិគាំពារសង្គមនឹងគិតគូរធ្វើបច្ចុប្បន្នភាព **ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥** ឱ្យកាន់តែប្រសើរ ដើម្បីឆ្លើយតបទៅនឹងទិសដៅគោលនយោបាយនេះ ក៏ដូចជាការវិវឌ្ឍថ្មីៗ, ទាំងក្នុងបរិបទកម្ពុជា, ក៏ដូចជាបរិបទតំបន់ និង សកល ។

ក្នុងស្មារតីនេះ, ដើម្បីបន្តជំរុញការអភិវឌ្ឍប្រព័ន្ធសន្តិសុខសង្គមនៅកម្ពុជា, ក្នុងនាមជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម និង ក្នុងនាម **សម្តេចតេជោ នាយករដ្ឋមន្ត្រី**, ខ្ញុំសូមផ្តល់នូវអានុសាសន៍មួយចំនួន ដល់ **ប.ស.ស.** ដូចខាងក្រោម៖

១- ត្រូវបង្កើនប្រសិទ្ធភាព ក្នុងការផ្តល់សេវាជូនសមាជិករបស់ខ្លួន តាមរយៈការធ្វើឌីជីថលូបនីយកម្មនៃប្រព័ន្ធប្រតិបត្តិការរបស់ខ្លួន;

២- ត្រូវបន្តពង្រឹងតម្លាភាព និង គណនេយ្យភាពស្ថាប័ន តាមរយៈការរៀបចំរបាយការណ៍ហិរញ្ញវត្ថុស្របតាមស្តង់ដា ដែលជាកម្មវត្ថុនៃការត្រួតពិនិត្យដោយសវនករឯករាជ្យ និង ដែលត្រូវបោះពុម្ពផ្សាយជាសាធារណៈ នាគ្រាបន្ទាប់;

៣- ត្រូវសហការជាមួយក្រសួងសុខាភិបាល ដើម្បីពង្រឹងយន្តការតាមដានគុណភាពនៃការផ្តល់សេវារបស់មូលដ្ឋានសុខាភិបាលដែលជាដៃគូ;

៤- ត្រូវសហការជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីបន្តជំរុញការចុះបញ្ជីក្រុមហ៊ុន, ពិសេសសហគ្រាសធុនតូច និង មធ្យម ដើម្បីឱ្យកម្មករ-និយោជិតនៃក្រុមហ៊ុនទាំងនោះ អាចក្លាយជាសមាជិកនៃ **ប.ស.ស.** ស្របតាមបទប្បញ្ញត្តិជាធរមាន;

៥- ត្រូវរៀបចំយន្តការដាក់ឱ្យដំណើរការ នូវកម្មវិធីឧបត្ថម្ភសាច់ប្រាក់ ជូនកម្មករ-និយោជិតជាស្ត្រី ក្នុងអំឡុងពេលមានផ្ទៃពោះ, ពេលសម្រាល និង ក្រោយសម្រាល រហូតដល់កូនមានអាយុ ២ ឆ្នាំ;

៦- ត្រូវចូលរួមអនុវត្តរបបថែទាំសុខភាព តាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល សម្រាប់បុគ្គលបម្រើការក្នុងសេវាកម្សាន្តទេសចរណ៍នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ; និង

៧- ត្រូវសហការជាមួយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម ដើម្បីបន្តពិនិត្យលទ្ធភាពពង្រីកវិសាលភាពរបបសន្តិសុខសង្គម ទៅកាន់ពលរដ្ឋគោលដៅផ្សេងៗបន្ថែមទៀត, ជាពិសេស អ្នកនៅក្នុងបន្ទុករបស់កម្មករ-និយោជិត និង មន្ត្រីសាធារណៈ ព្រមទាំងពលរដ្ឋនៃវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ។

ខ្ញុំមានជំនឿថា អគារស្នាក់ការកណ្តាលថ្មីរបស់ **ប.ស.ស.** នេះ នឹងរួមចំណែកក្នុងការ-បង្កើនប្រសិទ្ធភាព និង ផ្តល់ភាពងាយស្រួល ក្នុងការផ្តល់សេវាជូនសមាជិក **ប.ស.ស.** ឱ្យបានកាន់តែប្រសើរឡើងបន្ថែមទៀត ។ ខ្ញុំក៏សូមស្នើឱ្យថ្នាក់ដឹកនាំ, មន្ត្រី និង បុគ្គលិកទាំងអស់នៃ **ប.ស.ស.** យកចិត្តទុកដាក់ខ្ពស់ ក្នុងការថែទាំអគារថ្មីនេះ ឱ្យបានល្អ និង ស្អាត សម្រាប់ការប្រើប្រាស់យូរអង្វែងទៅអនាគត ។

មុននឹងបញ្ចប់, ក្នុងឱកាសដ៏ថ្លៃថ្លានេះ, ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះ ឯកឧត្តមបណ្ឌិត **អ៊ិត សំហេង**, ក្នុងនាមឯកឧត្តមជារដ្ឋមន្ត្រីក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ផង, និង ក្នុងនាមជាប្រធានក្រុមប្រឹក្សាភិបាលរបស់ **ប.ស.ស.** ផង, ចំពោះការចូលរួមចំណែកយ៉ាងធំធេង ក្នុងការអភិវឌ្ឍប្រព័ន្ធសន្តិសុខសង្គមនាពេលកន្លងមក ។ ជាមួយគ្នានេះ, ខ្ញុំក៏សូមកោតសរសើរផងដែរ ចំពោះ ឯកឧត្តម **អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក **ប.ស.ស.** ដែលបានដឹកនាំ **ប.ស.ស.** ចាប់តាំងពីថ្ងៃកកើតដំបូង រហូតដល់បច្ចុប្បន្ន ដោយសម្រេចបានលទ្ធផលជាផ្លែផ្កាជាច្រើន គួរឱ្យកត់សម្គាល់ ។

ខ្ញុំក៏សូមកោតសរសើរថ្នាក់ដឹកនាំ, មន្ត្រី និង បុគ្គលិកទាំងអស់ នៃ **ប.ស.ស.** ដែលខិតខំអស់ពីកម្លាំងកាយចិត្ត ក្នុងការបំពេញការងារបម្រើសេវាសាធារណៈ ជូនសមាជិករបស់ខ្លួនប្រកបដោយការទទួលខុសត្រូវ និង វិជ្ជាជីវៈ ។ ទន្ទឹមនេះ, ខ្ញុំក៏សូមវាយតម្លៃខ្ពស់ចំពោះក្រសួង-ស្ថាប័នពាក់ព័ន្ធ និង ដៃគូអភិវឌ្ឍន៍នានា ដែលតែងសហការ និង គាំទ្រដល់ការអនុវត្ត

ការងាររបស់ **ប.ស.ស.** ដោយបានចូលរួមចំណែកធ្វើឱ្យអង្គភាពមួយនេះ ទទួលបាននូវជោគជ័យ និង សម្រេចបាននូវសមិទ្ធផលជាច្រើនជូនសង្គមជាតិ ។ ខ្ញុំសូមលើកទឹកចិត្តឱ្យគ្រប់ក្រសួង-ស្ថាប័ន, ដៃគូអភិវឌ្ឍន៍ និង ភាគីពាក់ព័ន្ធទាំងអស់ បន្តចូលរួមគាំទ្រ **ប.ស.ស.**, ទាំងបច្ចេកទេស និង ហិរញ្ញវត្ថុ, ដើម្បីអភិវឌ្ឍន៍ប្រព័ន្ធសន្តិសុខសង្គមកម្ពុជា ឱ្យក្លាយជាប្រព័ន្ធមួយដែលមានប្រសិទ្ធភាព, ចីរភាព, ភាពធន់, សមធម៌ និង បរិយាប័ន្ន ។

ជាទីបញ្ចប់, ខ្ញុំសូមប្រសិទ្ធពរជ័យជូន **ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, ឧកញ៉ា, លោក, លោកស្រី,** ប្រកបដោយសុខភាពល្អបរិបូរណ៍, សុភមង្គលក្នុងក្រុមគ្រួសារ និង ទទួលបានជោគជ័យក្នុងគ្រប់ភារកិច្ច ក្រោមម្លប់ដ៏ត្រជាក់នៃសុខសន្តិភាពទូទាំងផ្ទៃប្រទេស ដែល **សម្តេចតេជោ នាយករដ្ឋមន្ត្រី** បាននាំមកជូនប្រជាជន និង ប្រទេសជាតិយើង ។

**ក្នុងនាមសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា,** ខ្ញុំសូមប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការ នូវ **អគារស្នាក់ការកណ្តាលរបស់បេឡាជាតិសន្តិសុខសង្គម** ចាប់ពីពេលនេះតទៅ ៕

***សូមអរគុណ!***